00870476

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion Roi
Royaume du Cambodge

E238/12

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 12 / 2012
ម៉ោង (Time/Heure): 10 : 10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២

សាធារណៈ / Public

**ផ្ញើជូន៖** មេធាវីការពារក្តី អៀង សារី
សហព្រះរាជអាជ្ញា
សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ការិយាល័យរដ្ឋបាល

**កម្មវត្ថុ៖ អនុស្សរណៈផ្ញើជូនក្រុមវេជ្ជបណ្ឌិតដែលមានភារកិច្ចពិនិត្យ ព្យាបាល និងថែទាំសុខភាព អៀង សារី នៅមន្ទីរឃុំឃាំង អ.វ.ត.ក**

អង្គជំនុំជម្រះសាលាដំបូងសូមយោងទៅដល់សេចក្តីសម្រេចរបស់ខ្លួនពាក់ព័ន្ធនឹងសម្បទារបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ (ឯកសារលេខ E238/9)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ (ឯកសារលេខ E238/4) និងការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ (ប្រតិចារឹក ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២) គឺជាមូលដ្ឋានសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា អៀង សារី នៅមានសម្បទាក្នុងការចូលរួមការជំនុំជម្រះបាន។ ដើម្បីបង្កើតជាវិធានសមស្របមួយដែលចាំបាច់ក្នុងការធានាឱ្យ អៀង សារី អាចចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនោះ អង្គជំនុំជម្រះសាលាដំបូងសូមណែនាំដល់ក្រុមវេជ្ជបណ្ឌិតដែលទទួលភារកិច្ច ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទរូបនេះ ឱ្យអនុវត្តដូចខាងក្រោម៖

១. របាយការណ៍ជារៀងរាល់ថ្ងៃ និងដោយផ្ទាល់មកអង្គជំនុំជម្រះសាលាដំបូង មុនពេលចាប់ផ្តើមសវនាការរៀងរាល់ព្រឹក និងបើចាំបាច់ ក្នុងពេលណាមួយនៅពេលថ្ងៃ។

២. របាយការណ៍គួរបញ្ចូលតែការប្រែប្រួលសំខាន់ៗចំពោះស្ថានភាពសុខភាពរបស់ អៀង សារី ដែលខុសពីសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់អ្នកជំនាញតែប៉ុណ្ណោះ។

៣. ជាងនេះទៀត ប្រសិនបើក្រុមវេជ្ជបណ្ឌិតដែលមានភារកិច្ចពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទមានយោបល់ផ្សេងៗទាក់ទងនឹងសម្ភារៈបរិក្ខារដែលបំពាក់នៅក្នុងបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការដែលអាចជួយបង្កើនសមត្ថភាពរាងកាយរបស់ អៀង សារី ក្នុងការចូលរួមសវនាការនោះ សូមបញ្ចូលយោបល់ទាំងនេះទៅក្នុងរបាយការណ៍ផងដែរ។


ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh
Original EN: 00869230-00869230